វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

FAIR FINANCE CAMBODIA
A MEMBER OF FAIR FINANCE ASIA

# សេចក្តីសង្ខេប របាយការណ៍សិក្សាអំពីការ

# “អនុវត្តគោលនយោបាយផ្តល់ហិរញ្ញប្បទានបៃតងនៅក្នុងប្រទេសកម្ពុជា”

**គាំទ្រដោយៈ**

People Change the World Diakonia

OXFAM

FAIR FINANCE ASIA

## ១. សេចក្តីផ្តើម

វិស័យហិរញ្ញវត្ថុ និងធនាគារ បានដើរតួនាទីយ៉ាងសំខាន់ និងជាយន្តការមួយក្នុងការជំរុញឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងជានាបាននូវលំហូរសាច់ប្រាក់ និងការធ្វើចរាចរណ៍រូបិយប័ណ្ណជាភារកិច្ចសំខាន់ ក្នុងការបង្កើនសកម្មភាពសេដ្ឋកិច្ចទាំងជាតិ និងទាំងប្រជាពលរដ្ឋដែលកំពុងប្រករបរចិញ្ចឹមជីវិត។ ការកើនឡើងនូវវត្តមាន និងបរិមាណជាច្រើននៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាជាសក្ខីភាពបញ្ជាក់យ៉ាងច្បាស់នូវកំណើនសកម្មភាពសេដ្ឋកិច្ច ក្នុងនោះរួមមានការកើនឡើងនូវគម្រោងវិនិយោគឬគម្រោងអភិវឌ្ឍន៍ទាំងឡាយ ដែលបានស្នើឡើងតាមគោលនយោបាយអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា។ ជាក់ស្តែងណាស់ ការខូចខាតនានាទៅលើធនធានពីសកម្មភាពរបស់គម្រោងអភិវឌ្ឍន៍ ក៏ជាការចូលរួមចំណែកដោយប្រយោលពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលបានផ្តល់កម្ចី ដោយសារការខ្វះខាតនូវតម្រូវការពេញលេញអំពីផលប៉ះពាល់បរិស្ថាន និងសង្គមនេះ មិនត្រឹមតែធ្វើឱ្យខូចខាតធនធានតែប៉ុណ្ណោះទេ តែថែមទាំងអាចបង្កឱ្យគម្រោងរបស់ខ្លួនបរាជ័យ និងមិនអាចមានលទ្ធភាពសងត្រឡប់ទៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុវិញ។ ការសិក្សាមួយនាពេលថ្មីៗនេះ អំពីការអនុវត្តកាតព្វកិច្ចការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ដែលដឹកនាំស្រាវជ្រាវដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ព្រមទាំងសមាជិកសម្ព័ន្ធហិរញ្ញវត្ថុយុត្តិធម៌កម្ពុជា បានរកឃើញអំពីជម្រើសគោលនយោបាយខ្លះដែលអាចប្រើប្រាស់សម្រាប់ជម្រុញការចូលរួមជាមួយវិស័យធនាគារ នៅក្នុងឆមាសទី១ នៃឆ្នាំ២០២១។

ក្រៅពីធនាគារ តួអង្គវិស័យនានា បានកើតឡើងក្នុងទម្រង់ផ្សេងៗគ្នាជាច្រើន ដើម្បីសម្របសម្រួលទីផ្សារហិរញ្ញវត្ថុទាំងឡាយ ដើម្បីឆ្លើយតបនឹងការអភិវឌ្ឍ និងការរីកចម្រើនវិស័យម៉ាក្រូសេដ្ឋកិច្ចសង្គមថ្មីៗនេះ។ ក្នុងចំណោមនោះ និយ័តករមូលបត្រកម្ពុជា ដើរតួនាទីយ៉ាងសំខាន់មួយ ជាស្ថាប័ននិយ័តករដ៏មានសក្តានុពលលើដំណើរការជួញដូរមូលបត្រនៅក្នុងប្រទេសកម្ពុជា ដែលមានសារៈសំខាន់ក្នុងការលើកស្ទួយការដាក់បញ្ចូលក្របខ័ណ្ឌអភិបាលកិច្ចបរិស្ថាន សង្គម ដូច្នេះដើម្បីយល់ពីគោលនយោបាយ និងបទបញ្ជា សំដៅឆ្ពោះទៅរកចីរភាពនៅក្នុងក្របខណ្ឌអភិបាលកិច្ចបរិស្ថាន សង្គម តម្រូវឲ្យមានការសិក្សាស៊ីជម្រៅមួយ។

សម្រាប់វិស័យបរិស្ថាន បទប្បញ្ញត្តិសំខាន់ៗមានដូចជា៖ (១) ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ១៩៩៦, (២)អនុក្រឹត្យលេខ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្នាំ១៩៩៩, (៣) ប្រកាសលេខ ៣៧៦ ប្រក.បស្ថ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងឆ្នាំ២០០៩, (៤) ប្រកាសលេខ០២១ ប្រក.បស្ថ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំ២០២០ និង (៥) អនុក្រឹត្យពាក់ព័ន្ធផ្សេងៗទៀតស្តីពីការគ្រប់គ្រងការបំពុលបរិស្ថាន និងប្រកាសស្តីពីការប្រើប្រាស់ក្របខណ្ឌយោងការងារសម្រាប់គម្រោងអភិវឌ្ឍន៍ខ្លះ។

អង្គការមិនមែនរដ្ឋាភិបាល ចង់ឃើញតួអង្គវិស័យហិរញ្ញវត្ថុ និងធនាគារ រួមទាំងនិយ័តករទាំងឡាយ គិតគូរពីបញ្ហាសង្គម និងបរិស្ថានដោយយកចិត្តទុកដាក់បំផុត ដោយជៀសវាងការផ្តល់ហិរញ្ញប្បទានដល់គម្រោង/ក្រុមហ៊ុនដែលបង្កទំនាស់ និងធ្វើឲ្យមានផលប៉ះពាល់មិនល្អ និងដាក់សម្ពាធទៅលើអតិថិជនដែលមានស្រាប់ និងថ្មី ឲ្យផ្លាស់ប្តូរការប្រព្រឹត្តិរបស់ពួកគេ ឲ្យស្របជាមួយនឹងស្តង់ដារអន្តរជាតិ និងច្បាប់ និងបញ្ញត្តិជាតិដើម្បីលើកស្ទួយ អភិបាលកិច្ចបរិស្ថាន សង្គមនៅកម្ពុជា។

## ២. គោលបំណង និងគោលដៅ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះគឺ ពិនិត្យមើលទីផ្សារមូលធនជាមួយនឹងការផ្តោតលើនិយ័តករ មូលបត្រកម្ពុជា និងបញ្ហាប្រឈមនានានៃការអនុវត្តគោលនយោបាយផ្តល់ហិរញ្ញប្បទានបៃតង និងការជំរុញការអនុវត្តលើការដាក់បញ្ចូលលក្ខណៈវិនិច្ឆ័យអភិបាលកិច្ចបរិស្ថានសង្គម និងសិទ្ធិមនុស្សនៅក្នុងវិស័យហិរញ្ញវត្ថុដោយរដ្ឋាភិបាលថ្នាក់ជាតិ និងនិយ័តករវិស័យហិរញ្ញវត្ថុផ្សេងៗទៀត ព្រមទាំងធន្ទះនយោបាយដែលប្រសើរឡើងក្នុងចំណោមអ្នកមានឥទ្ធិពល។

គោលដៅ នៃការសិក្សានេះ រួមមានដូចខាងក្រោម៖

១. ដើម្បីកំណត់បទប្បញ្ញត្តិ និងតម្រូវការហិរញ្ញប្បទានបៃតងដែលនិយ័តករមូលបត្រកម្ពុជា គ្រប់គ្រង (ដោយសង្កត់ធ្ងន់ជាពិសេសលើអភិបាលកិច្ចបរិស្ថានសង្គម (ESG) បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ជាមួយនឹងលក្ខណៈវិនិច្ឆ័យរបស់ UNGP និងវិធីសាស្ត្រហិរញ្ញប្បទានយុត្តិធម៌អន្តរជាតិ រួមទាំងប៉ុន្តែមិនកំណត់ចំពោះគោលការណ៍ ESG ផ្សេងទៀតដូចជា គោលការណ៍អេក្វាទ័រ និងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាព)។

២. ដើម្បីពិនិត្យមើលវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការពង្រឹងដំណើរការបទប្បញ្ញត្តិទាំងនេះ និងនិន្នាការនៃការអនុវត្តបទប្បញ្ញត្តិហិរញ្ញប្បទានបៃតងដោយ SERC និងសម្រាប់គោលនយោបាយអ្នកចូលរួមទីផ្សាររបស់ SERC ។

៣. ដើម្បីបង្កើតគោលនយោបាយហិរញ្ញប្បទានបៃតងដោយសង្ខេបអំពីជម្រើសជំនួសសម្រាប់ការអនុវត្តគោលនយោបាយហិរញ្ញប្បទានបៃតងកាន់តែប្រសើរឡើងនៅកម្ពុជា។

៤. ដើម្បីលើកឡើងនូវអនុសាសន៍លើគោលនយោបាយស្តីពីការផ្តល់ហិរញ្ញប្បទានបៃតង និងជម្រុញ ការចូលរួមពង្រឹងការអនុវត្តន៍គោលនយោបាយស្តីពីការផ្តល់ហិរញ្ញប្បទានបៃតង និងការដាក់បញ្ចូលក្របខ័ណ្ឌលក្ខណៈវិនិច្ឆ័យអភិបាលកិច្ចបរិស្ថាន សង្គម និងសិទ្ធិមនុស្សនៅក្នុងនិយ័តករមូលបត្រកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន រួមទាំង ADB, WB, AIIB, UNFCC, NBC, ABC, MFI, SERC និងសមាជិកសម្ព័ន្ធភាពយុត្តិធម៌ហិរញ្ញវត្ថុនៅកម្ពុជា។

## ៣. វិធីសាស្ត្រ

ការសិក្សានេះប្រើប្រាស់នូវវិធីសាស្ត្របែបគុណភាពសម្រាប់ការប្រមូលព័ត៌មាន និងទិន្នន័យក្នុងការវិភាគ និងធ្វើរបាយការណ៍ស្តីពីការរកឃើញ និងអនុសាសន៍នានា។ វិធីសាស្ត្រខាងក្រោមនេះត្រូវបានប្រើសម្រាប់ការសិក្សានេះ៖

### ក. ការប្រមូលព័ត៌មាន និងទិន្នន័យបន្ទាប់បន្សំ

សម្រាប់ការប្រមូលទិន្នន័យ ឬព័ត៌មានបន្ទាប់បន្សំ អ្នកសិក្សាស្រាវជ្រាវនឹងពិនិត្យទៅលើឯកសារ, របាយការណ៍, ឬធនធានបញ្ញាដែលមានស្រាប់អំពីគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត និងការប្រតិបត្តិនានាអំពីការអនុវត្តន៍គោលនយោបាយនានា នៃការផ្តល់ហិរញ្ញប្បទានបៃតង និងការពង្រឹងការដាក់បញ្ចូលលក្ខណៈវិនិច្ឆ័យអភិបាលកិច្ចបរិស្ថាន សង្គម និងសិទ្ធិមនុស្សទៅក្នុងវិស័យហិរញ្ញវត្ថុ ជាពិសេស និយ័តករមូលបត្រ

កម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន រួមទាំងរដ្ឋាភិបាលជាតិ និងនិយ័តករវិស័យហិរញ្ញវត្ថុផ្សេងៗទៀត និងបទពិសោធន៍ផ្សេងៗជាច្រើនទៀតដែលអាចបានប្រមូលបាន។

ការរៀបចំធ្វើបណ្ណាល័យសាស្ត្រនឹងចងក្រងនូវឯកសារនានាពីការសិក្សាស្រាវជ្រាវមុនៗ និងការសិក្សានាពេលបច្ចុប្បន្ន ឬពីលទ្ធផលគម្រោងដែលបានអនុវត្តក្នុងប្រទេសកម្ពុជា។ ប្រភពព័ត៌មាន, ទិន្នន័យ, និងឯកសារទាំងនេះមាននៅតាមបណ្ណាល័យ, សាកលវិទ្យាល័យ, ស្ថាប័នរដ្ឋ, អង្គការមិនមែនរដ្ឋាភិបាល, និងអង្គភាពដែលពាក់ព័ន្ធផ្សេងៗទៀត។ លើសពីនេះទៀត អ្នកសិក្សាស្រាវជ្រាវនឹងស្វែងរកឯកសារមួយចំនួនពីប្រភពគេហទំព័ររបស់ស្ថាប័នធនាគារធំៗ និងស្ថាប័ននានារបស់រដ្ឋាភិបាល ដូចជា គេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា, គេហទំព័ររបស់សមាគមធនាគារនៃកម្ពុជា, និងគេហទំព័ររបស់ធនាគារឯកជនមួយចំនួនផងដែរ ព្រមទាំងរបស់ក្រសួងបរិស្ថានផងដែរ។ ក្រៅអំពីនេះ ឯកសារផ្សេងៗទៀតដូចជាសៀវភៅ, អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ, និក្ខេបបទ, និងរបាយការណ៍ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងប្រធានបទនៃការសិក្សានេះ ក៏នឹងត្រូវបានយកមកប្រើប្រាស់សម្រាប់ជាប្រយោជន៍ដល់ការចងក្រងរបាយការណ៍នេះ។

## ខ. ការប្រមូលព័ត៌មាន និងទិន្នន័យបឋម

សម្ភាសន៍ជាមួយជនបង្គោល៖ អ្នកសិក្សានឹងស្នើសុំជួបសម្ភាសន៍ដាច់ដោយឡែកៗពីគ្នាជាមួយជនបង្គោលទាំងឡាយដែលអាចពិភាក្សា ចែករំលែក និងផ្លាស់ប្តូរមតិយោបល់និងបទពិសោធន៍នានាអំពីការអនុវត្តន៍គោលនយោបាយនានា នៃការផ្តល់ហិរញ្ញប្បទានបៃតង និងការពង្រឹងការដាក់បញ្ចូលលក្ខណៈវិនិច្ឆ័យអភិបាលកិច្ចបរិស្ថាន សង្គម និងសិទ្ធិមនុស្សទៅក្នុងទីផ្សារមូលធន និយ័តករមូលបត្រកម្ពុជា និងដោយរដ្ឋាភិបាលជាតិ និងនិយ័តករវិស័យហិរញ្ញវត្ថុផ្សេងៗទៀត។ ស្ថាប័ន ឬអង្គភាពដែលនឹងត្រូវជួបធ្វើសម្ភាសន៍រួមមាន៖

១. និយ័តករមូលបត្រកម្ពុជា

២. ធនាគារជាតិនៃកម្ពុជា (NBC) - ស្ថាប័ននេះជាអង្គភាពគ្រប់គ្រងកំពូលលើប្រព័ន្ធ និងការធ្វើអាជីវកម្មធនាគារនៅក្នុងប្រទេសកម្ពុជា ដើម្បីស្វែងយល់អំពីគោលដៅ និងវិធីសាស្ត្រដែលធនាគារជាតិនៃកម្ពុជា បានដាក់ចេញក្នុងការអនុវត្ត។

៣. ការរៀបចំឲ្យមាននូវសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធផ្សេងៗ រួមមាន ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, តំណាងធនាគារជាតិនៃកម្ពុជា និងអង្គការសង្គមស៊ីវិលនានានឹងត្រូវបានអញ្ជើញឱ្យចូលរួមដើម្បីធ្វើការផ្សព្វផ្សាយ, ចែករំលែកលទ្ធផល, និងប្រមូលបន្ថែមនូវធាតុចូល សម្រាប់ការពង្រឹងការដាក់បញ្ចូលលក្ខណៈវិនិច្ឆ័យអភិបាលកិច្ចបរិស្ថាន សង្គម និងសិទ្ធិមនុស្សទៅក្នុងទីផ្សារមូលធន និយ័តករមូលបត្រកម្ពុជា និងដោយរដ្ឋាភិបាលជាតិ និងនិយ័តករវិស័យហិរញ្ញវត្ថុផ្សេងៗទៀត ។

## ៤. ការពិភាក្សាលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ

ធនាគារជាតិនៃកម្ពុជាយល់ឃើញថា គោលនយោបាយហិរញ្ញប្បទានបៃតង មានសារៈសំខាន់ក្នុងការធានាថា រាល់គម្រោងអភិវឌ្ឍន៍មានភាពបៃតង មិនប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន។ ពាក់ព័ន្ធនឹងហិរញ្ញប្បទានបៃតង ធនាគារជាតិនៃកម្ពុជា បានអនុម័តគោលការណ៍ណែនាំក្នុងការអនុវត្ត គោលការណ៍ហិរញ្ញប្បទានប្រកបដោយចីរភាព របស់កម្ពុជា (Cambodia Sustainable Finance Principles Implementation Guidelines) ដែលបានរៀបចំឡើងដោយសមាគមធនាគារនៅកម្ពុជា។

ធនាគារជាតិនៃកម្ពុជា បានផ្តល់ធាតុចូលដល់សមាគមអាស៊ាន សមាគមនអាស៊ានបានដាក់ចេញនូវវចនានុក្រម (taxonomy) [ហិរញ្ញប្បទានប្រកបដោយចីរភាព] ដើម្បីដាក់ឲ្យប្រើប្រាស់ក្នុងខែវិច្ឆិកា ឆ្នាំ ២០២១នេះ ដែលវចនានុក្រមនេះ នពិពណ៌នា អំពីស្តង់ដារមូលប័ត្របៃតង ហិរញ្ញប្បទានប្រកបដោយចីរភាព និងហេដ្ឋារចនាសម្ព័ន្ធ។ ចំពោះវឌ្ឍនភាពនៃការអនុវត្តហិរញ្ញប្បទានប្រកបដោយចីរភាព ធនាគារពិភពលោក បានមើលឃើញថា ប្រទេសកម្ពុជាកំពុងតែរំកិលពីដំណាក់កាលអភិវឌ្ឍ ទៅកាន់ដំណាក់កាលអនុវត្ត។

ធនាគារជាតិនៃកម្ពុជាចាត់ទុកថាហិរញ្ញប្បទានបៃតងនេះក៏មិនមែនជាបរិបទថ្មីដែរ ក្នុងក្របខ័ណ្ឌដែលអង្គពាក់ព័ន្ធទាំងអស់មានចំណាប់អារម្មណ៍។ ការអភិវឌ្ឍ និងអនុវត្តនូវគោលនយោបាយហិរញ្ញប្បទានបៃតង មិនមែនជាតួនាទីរបស់ធនាគារជាតិ ឬស្ថាប័នណាមួយនោះ ទេ ពោលគឺទាមទារឲ្យមានការចូលរួមពីសំណាក់តួអង្គពាក់ព័ន្ធ ក្នុងការបង្កើតជាប្រព័ន្ធអេកូឡូស៊ី (ecosystem)។ បច្ចុប្បន្ននេះសមត្ថភាព ក្នុងការអភិវឌ្ឍគោលនយោបាយក៏នៅមានកម្រិតផងដែរ។

គួររំលឹកផងដែរថា សមាគមធនាគារក្នុងប្រទេសកម្ពុជាបានដាក់ចេញនូវគោលការណ៍ហិរញ្ញប្បទានប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា ជាដំណាក់កាលមួយយ៉ាងសំខាន់ដែលឆ្លុះបញ្ចាំងអំពីការចាប់ផ្តើមយកចិត្តទុកដាក់ទៅលើបរិស្ថាន សង្គម និងវប្បធម៌ ហើយដែលជាផ្នែកមួយនៃទំនួលខុសត្រូវរបស់វិស័យធនាគាររបស់ព្រះរាជាណាចក្រកម្ពុជា ទោះបីជាការអនុវត្តគោលការណ៍នេះជាការស្ម័គ្រចិត្តក៏ដោយ។

និយ័តករមូលប័ត្រកម្ពុជា កំពុងតែគិតគូរលើការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងហិរញ្ញប្បទានបៃតង ដែលមានដូចជាមូលប័ត្របៃតងជាដើម។ ការងារជាអាទិភាពរបស់និយ័តករមូលប័ត្រកម្ពុជា នាពេលបច្ចុប្បន្នគឺការធានានូវចីរភាពសេដ្ឋកិច្ចតាមរយៈការទាក់ទាញអ្នកវិនិយោគ ដើម្បីកំណើនសេដ្ឋកិច្ច និងការងាររបស់ប្រជាជនកម្ពុជា ខណៈបញ្ហាបរិស្ថាន និងទំនួលខុសត្រូវសង្គមក៏ត្រូវបានចាត់ទុកថា មានសារៈសំខាន់ ប៉ុន្តែជាអាទិភាពបន្ទាប់។ ដូច្នេះការរៀបចំគោលនយោបាយហិរញ្ញប្បទានបៃតងសម្រាប់ដាក់ឲ្យវិនិយោគិនអនុវត្ត នឹងមិនត្រូវបានធ្វើឡើងឆាប់ដោយសារតែកត្តាសំខាន់ៗទាំងឡាយ រួមមាន៖ ការសិក្សាអំពីផលជះ នៃគោលនយោបាយ និងការរង់ចាំនូវវចនានុក្រម បៃតងអាស៊ានផងដែរ។

និយ័តករមូលប័ត្រកម្ពុជាក៏បានយល់ឃើញថា ការរៀបចំគោលនយោបាយ និងអនុវត្តគោលនយោបាយហិរញ្ញប្បទានបៃតងទាមទារឲ្យមាន នូវសមត្ថភាព និងការសិក្សាដោយផ្អែកលើភស្តុតាងឲ្យបានច្បាស់ផងដែរ។ ដូច្នេះការកសាងសមត្ថភាពចំពោះអ្នកពាក់ព័ន្ធជាកត្តាសំខាន់សម្រាប់សម្រេចបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ដោយសារតែប្រទេសកម្ពុជាកំពុងតែស្ថិតក្នុងដំណាក់កាលដំបូង ក្នុងការអភិវឌ្ឍគោលនយោបាយហិរញ្ញប្បទានបៃតង ខណៈពិភពលោកទាំងមូលកំពុងតែឯកភាពគ្នាអំពីសារៈសំខាន់នៃការដាក់បញ្ចូលនូវកត្តាបរិស្ថាន សង្គម និងអភិបាលកិច្ចនៅក្នុងការសម្រេចចិត្តបែបហិរញ្ញប្បទាន និងការវិនិយោគ ក្នុងបរិបទជំងឺកូវីដ១៩ ផងដែរ ដូច្នេះការទាមទារឲ្យមាននូវទំនួលខុសត្រូវយ៉ាងខ្លាំងក្លាពីសំណាក់វិស័យហិរញ្ញវត្ថុ ក្នុងការបែងចែកនូវមូលនិធិសម្រាប់វិនិយោគ ការចែករំលែកហានិភ័យ និងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដល់អ្នកគ្រប់គ្នា។ ស្ថាប័ននានារួមមានវិស័យឯកជន វិស័យសាធារណៈ និងអង្គការសង្គមស៊ីវិលគួរតែចៀសវាងការបន្លំដោយប្រកាសថាសកម្មភាពណាមួយជាសកម្មភាពបៃតង ខណៈដែលសកម្មភាពនោះមិនមានលក្ខណៈគ្រប់គ្រាន់នៅក្នុងនិយាមបៃតង។ ចំណុចសំខាន់មួយទៀតសម្រាប់របាយការណ៍ហរិញ្ញវត្ថុ គួរតែរំលិចឡើងនូវស្ថានភាព និងសកម្មភាពទាំងឡាយណាដែលសកម្មភាពអភិវឌ្ឍន៍ និងគម្រោងមានផលជះជាអវិជ្ជមាន ឬលើកកំពស់បរិស្ថានជាដើម។

សមាគមធនាគារនៅកម្ពុជា ទទួលបានការគាំទ្រពីធនាគារជាតិនៃកម្ពុជានិងក្រសួងបរិស្ថាន និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ដែលមានដូចជា IFC, USAID, WCS សមាគមនធនាគារអាស៊ាន និងរដ្ឋាភិបាលនៃប្រទេសម៉ុងហ្គោលី ដោយសារប្រទេសម៉ុងហ្គោលីកំពុងឈានទៅរកហិរញ្ញប្បទានបៃតង។ ក្នុងអំឡុងពេលអនុម័តគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា មានធនាគារនៅកម្ពុជាលើសពី ៥០ បានទទួលយកគោលការណ៍នេះ។ គណៈកម្មាធិការមានផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តគោលគារណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជាក្រោមធ័ត្រ ធនាគារជាតិនៃកម្ពុជា ក្រសួងបរិស្ថាន និងសមាគមធនាគារនៅកម្ពុជា ដោយផ្តោតទៅលើការកសាងសមត្ថភាព ព្រោះវានឹងជួយធនាគារ និងស្ថាប័នហិរញ្ញវត្ថុអនុវត្តគោលការបានជោគជ័យ។ ការកសាងសមត្ថភាពទាមទារឱ្យធនគារនិងស្ថាប័នហិរញ្ញវត្ថុនីមួយៗ មានបុគ្គលតំណាងមួយរូបដើម្បីចូលរួមកម្មវិធីបណ្តុះបណ្តាល។ បច្ចុប្បន្ន សមាគមធនាគារនៅកម្ពុជា កំពុងធ្វើការជាមួយសមាគមធនាកម្ពុជា ដើម្បីបង្កើតក្របខ័ណ្ឌ និងនីតិវិធីសម្រាប់ការអនុវត្តហិរញ្ញប្បទានបៃតង។ អ្វីដែលសំខាន់បំផុតគឺការបង្កើតក្របខ័ណ្ឌនិងនិយមន័យនៃហិរញ្ញប្បទានបៃតង ដែលវាទាមទារឱ្យមានការចូលរួមពីគ្រប់ភាគី។ លើសពីនេះ សមាគមធនាគារនៅកម្ពុជា បានក្លាយជាសមាជិកបណ្តាញធនាគារប្រកបដោយចីរភាព (SBN) អស់រយៈពេលបីឆ្នាំមកហើយ។ SBN បានផ្តល់នៅជំនួយបច្ចេកទេស ហើយតាមរយៈការវាយតម្លៃរបស់ SBN កម្ពុជាទទួលបានដំណើរការយ៉ាងល្អនៅក្នុងគោលការណ៍ហិរញ្ញប្បទានាបៃតង/ប្រកបដោយចីរភាព។

ធនាគារអភិវឌ្ឍន៍កសិកម្ម និងជនបទ (ARDB) ស្ថិតក្រោមក្រសួងសេដ្ឋកិច្ច កំពុងចាប់ផ្តើមអនុវត្តហិរញ្ញប្បទានបៃតងដោយស្របទៅតាមបំណងរបស់រាជរដ្ឋាភិបាល ដែលការផ្តួចផ្តើមនេះធ្វើឡើងចំពោះឧបករណ៍ហិរញ្ញវត្ថុដោយ

ពិនិត្យទៅលើហិរញ្ញប្បទានដែលមានស្រាប់ ដូចជាហិរញ្ញប្បទានពីមូលនិធិអាកាសធាតុបៃតង (GCF) តាមរយៈក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCDF) នៃក្រសួងបរិស្ថាន និងដែលជាលេខាធិការដ្ឋានរបស់រាជរដ្ឋាភិបាល។ មានគម្រោងមួយចំនួនកំពុងត្រូវបានអនុវត្តនៅកម្ពុជាក្រោមគម្រោងកម្ចីនិងជំនួយ។ ដើម្បីទទួលបានមូលនិធិពី GCF ធនាគារ ARDB កំពុងស្វែងរកដៃគូអនុវត្ត ដោយសារធនាគារអភិវឌ្ឍន៍ជនបទនិងសិកម្ម មិនអាចទទួលបានកម្ចីដោយផ្ទាល់។ ធនាគារ ARDB កំពុងធ្វើការជាមួយ FAO និង AFD ផងដែរ ដើម្បីបង្កើតទស្សនាទានសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជាក់ថា កម្ចីក្នុងស្រុកត្រូវគោរពតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣។ រាល់ម្ចីទាំងអស់ ត្រូវធ្វើការពិចារណាឱ្យបានច្បាស់លាស់ទៅលើទំហំកម្ចី ការប្រាក់ និង វិស័យអាទិភាព។ ហេតុដូចនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិចារណាទៅលើកម្ចីសម្បទាន និង/ឬកម្ចីណាដែលប្រើក្នុងវិស័យអាទិភាពតែប៉ុណ្ណោះ។ កម្ចីត្រូវប្រើប្រាស់ឱ្យមានតម្លាភាពនិងប្រសិទ្ធភាព និងទៅលើគម្រោងដែលជំរុញដល់ការអភិវឌ្ឍប្រកបដោយចីរភាព។ កន្លងមកនេះ រាជរដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយ ADB ក្នុងគម្រោងខ្សែច្រវ៉ាក់តម្លៃប្រកបដោយចីរភាព ជាមួយនឹងកម្ចី ១៤០ លានដុល្លារអាមេរិក ហើយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកអនុវត្តន៍។ ដើម្បីទទួលបានមូលនិធិពី GCF ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំពុងពិនិត្យមើលដៃគូដែលមានទំនុកចិត្ត ហើយ ARDB អាចជាដៃគូដែលមានសក្តានុពលក្នុងការទទួលបានមូលនិធិនិងផ្តល់កម្ចីដល់គម្រោងតូចៗ។

ការអនុវត្តគោលនយោបាយហិរញ្ញប្បទានបៃតងប្រឈមនឹងបញ្ហាមួយចំនួន។ ទី១ ហិរញ្ញប្បទានបៃតង មិនមាននិយមន័យឬលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ទោះបីជាមានគម្រោងមួយចំនួនបានអះអាងថាកំពុងអនុវត្តក្រោមគោលការណ៍បៃតង។ ហិរញ្ញប្បទានបៃតង អាចជាផ្នែកមួយនៃហិរញ្ញប្បទានប្រកបដោយចីរភាព ក៏ប៉ុន្តែដោយសារមិនមានគោលការណ៍ និយមន័យ និងលក្ខណៈវិនិច្ឆ័យ ធ្វើឱ្យមានការលំបាកក្នុងការសម្គាល់ថាតើគម្រោងណាមានលក្ខណៈបៃតង ហើយគម្រោងណាមិនមាភាពបៃតង។ ហេតុនេះ ភាគី ពាក់ព័ន្ធត្រូវយល់ឱ្យបានច្បាស់អំពីហិរញ្ញប្បទានបៃតងដោយផ្អែកទៅលើនិយមន័យ គោលការណ៍ និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់។ ជាទូទៅ គម្រោងធំៗត្រូវបានឆ្លងកាត់ EIA ។ ហិរញ្ញប្បទានបៃតងមានសារៈសំខាន់ក្នុងការធានាឱ្យបាននូវចីរភាពក្នុងបរិស្ថាន និងសង្គម ហើយក្នុងនេះដែរ វិស័យឯកជន គួរតែត្រូវបានលើកទឹកចិត្តឱ្យចូលរួម។ ទី២ ភាពលំបាកក្នុងការទំនាក់ទំនង ធ្វើឱ្យមានការលំបាកក្នុងការទទួលបានមូលនិធិពី GCF ដោយសារតែវាទាមទារឱ្យមានការយល់ច្បាស់លាស់អំពីលក្ខណៈវិនិច្ឆ័យពី GCF ដើម្បីទទួលបានមូលនិធិបៃតង។ ទី៣ គួរពិចារណាទៅលើបញ្ហានានាដូចជាហានិភ័យបច្ចេកវិទ្យា ដោយគួរមានការសិក្សាអំពីហានិភ័យពាក់ព័ន្ធទៅនឹងគម្រោងកសិដ្ឋានថាមពលពន្លឺព្រះអាទិត្យ។ ក្រៅពីហានិភ័យបច្ចេកវិទ្យា គួរពិចារណាទៅលើការពង្រឹងកិច្ចសន្យាផងដែរ។ ទី៤ ដើម្បីជំរុញដល់ហិរញ្ញប្បទានបៃតង ចាំបាច់ត្រូវកំណត់តួនាទីនិងភារៈកិច្ចច្បាស់លាស់សម្រាប់អ្នកអនុវត្ត។

ដើម្បីបង្កើត និងអនុវត្តគោលនយោបាយហិរញ្ញប្បទានបៃតង ត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដែលរួមមាន រដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល។ បន្ថែមលើនេះ ត្រូវមានការប្តេជ្ញាក្នុងការអនុវត្តហិរញ្ញប្បទានបៃតង។ ការរៀនសូត្រពីបទពិសោធន៍ជោគជ័យពីប្រទេសនានា អាចជួយដល់កម្ពុជាបង្កើតនិងអនុវត្តគោលនយោបាយបៃតង។ ការតាមដាននិងវាយតម្លៃគួរធ្វើឡើងជាប្រចាំដើម្បីធានាថាដំណើរការនៃការអនុវត្តមានភាពត្រឹមត្រូវ។ ជាចុងក្រោយ អ្នកតាក់តែងគោលនយោបាយ គួរត្រូវបានលើកទឹកចិត្តក្នុងការកាត់បន្ថយហានិភ័យ ហើយស្ថាប័នហិរញ្ញវត្ថុ គួរត្រូវបានលើកទឹកចិត្តឱ្យអនុវត្ត និងផ្តល់របាយការណ៍ត្រឹមត្រូវ។ បច្ចុប្បន្ន មានស្ថាប័នហិរញ្ញវត្ថុមួយចំនួនប៉ុណ្ណោះដែលបានផ្តល់របាយការណ៍ទាក់ទងនឹងចីរភាព ហើយធនាគារ ACLEDA ជាស្ថាប័នមួយក្នុងចំណោមស្ថាប័នទាំងនោះ។

តាមទស្សនៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការបង្កើតគោលនយោបាយហិរញ្ញប្បទានបៃតងត្រូវពិនិត្យមើលផ្នែកតម្រូវការ បើគ្មានតម្រូវការទេ វានឹងមិនអាចអនុវត្តបាន។ ប្រសិនបើមានការសិក្សាតាមដានបន្ទាប់ វិធីសាស្ត្រគួរតែរួមបញ្ចូលការវិភាគលើផ្នែកតម្រូវការ ដែលតម្រូវការហិរញ្ញប្បទានបៃតងអាចជាសក្តានុពលសម្រាប់ហិរញ្ញប្បទានបៃតងនៅកម្ពុជា។ ម្យ៉ាងទៀត បើមានការវិនិយោគលើថាមពលបៃតង តើមានតម្រូវការទេ? អ្នកផ្តល់ហិរញ្ញប្បទានបៃតងនៅកម្ពុជាមានសក្តានុពលគឺ GCF ។ គម្រោងមូលនិធិដ៏ធំមួយដែលផ្តល់ហិរញ្ញប្បទានដោយ GCF គឺ "គម្រោងខ្សែច្រវ៉ាក់ផលិតកម្មប្រកបដោយភាតរៈបរិស្ថាន ( Climate Friendly Agribusiness Value Chains - CFAVCSP)" មានក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ជាភ្នាក់ងារប្រតិបត្តិគម្រោង និងមានការចូលរួមអនុវត្តដោយក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ។ ទឹកប្រាក់សរុបសម្រាប់គម្រោងនេះ ចំនួន ១៤១ លានដុល្លារអាមេរិក ដែលជា សហហិរញ្ញប្បទានរវាង ADB, GCF, បដិភាគរបស់រាជរដ្ឋាភិបាល និងបដិភាគពីការចូលរួមអ្នកទទួលផល ផងដែរ។ រយៈពេលអនុវត្ត ២០១៨ - ២០២៤។

ហិរញ្ញប្បទានបៃតងគឺជាបញ្ហាអន្តរវិស័យ ដូច្នេះ ការបង្កើតក្របខណ្ឌធំទូលាយមួយសម្រាប់វានឹងផ្តល់នូវមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍គោលនយោបាយហិរញ្ញប្បទានបៃតង ហើយចាំបាច់ត្រូវមាននិយមន័យច្បាស់លាស់។ ប្រសិនបើដើម្បីបង្កើតផែនការមេហិរញ្ញប្បទានបៃតង ចាំបាច់ត្រូវកំណត់ភ្នាក់ងារនាំមុខ និងភ្នាក់ងារសម្របសម្រួល។ ដើម្បីអនុវត្តគោលនយោបាយហិរញ្ញប្បទានបៃតង ចាំបាច់ត្រូវមានធនធានមនុស្សក្នុងផ្នែកគ្រប់គ្រងគម្រោង ការអនុវត្តគម្រោង ការត្រួតពិនិត្យ និងការអនុវត្តស្របតាមស្តង់ដារ និងច្បាប់។

## ៥. អនុសាសន៍សំខាន់ៗ

**អនុសាសន៍ទី១៖** លើកកំពស់ការយល់ដឹង និងកសាងសមត្ថភាពដល់បុគ្គលិកអាជីព អ្នកអនុវត្ត និងអ្នកវិនិយោគ ដែលត្រូវរៀបចំឡើងដោយធនាគារជាតិកម្ពុជា ដល់ធនាគាររឹក ដែលផ្តោតទៅលើនិយមន័យ និងគុណវុឌ្ឍិ សម្រាប់ហិរញ្ញប្បទានបៃតង។

**អនុសាសន៍ទី ២៖** ស្ថាប័នហិរញ្ញវត្ថុគួរតែគិតសារឡើងវិញ នូវតួនាទីរបស់ពួកគេនៅក្នុងសង្គម ដោយបង្កើតនូវគោលនយោបាយច្បាស់លាស់ និងប្រកបដោមហិច្ឆតាក្នុងការលើកកំពស់បរិស្ថាន និងសង្គម និងអភិបាលកិច្ច ដោយដាក់បញ្ចូលនូវនិយាមអន្តរជាតិ នៅក្នុងគោលនយោបាយ និងបញ្ញត្តិស្តីអំពីហិរញ្ញប្បទានបៃតង។

**អនុសាសន៍ទី ៣៖** លើកទឹកចិត្តដល់សមាជិកនៃសមាគមធនាគារក្នុងប្រទេសកម្ពុជា ក្នុងការអនុវត្តនូវគោលការហេរិញ្ញប្បទានប្រកបដោយចីរភាព ហើយធនាការជាតិនៃកម្ពុជាគួរតែផ្តល់រង្វាន់លើកទឹកចិត្ត ធនាគារទាំងឡាយណាដែលបានអនុវត្តគោលការណ៍បានពេញលេញ ដូចជាការលើកទឹកចិត្តក្នុងការលើកលែងពន្ធជាដើម។

**អនុសាសន៍ទី ៤៖** ការសិក្សាផ្អែកលើភស្តុតាង គួរតែត្រូវធ្វើឡើងដោយធនាគារជាតិនៃកម្ពុជា សម្រាប់ប្រើបាស់ជាសក្ខីភាព ក្នុងការបង្កើតនូវគោលការណ៍ណែនាំ និងបញ្ញត្តិពាក់ព័ន្ធទៅនឹងហិរញ្ញប្បទានបៃតងក្នុងប្រទេសកម្ពុជា ហើយការបង្កើតគោលការណ៍ណែនាំ និងបញ្ញត្តិគួរតែធ្វើឡើងផ្អែកទៅលើវចនានុក្រមអាស៊ានស្តីអំពីប្រភេតអាជីវកម្មបៃតង ដោយរួមបញ្ចូលនូវតួអង្គពាក់ព័ន្ធផងដែរ។

**អនុសាសន៍ទី ៥៖** អ្នករៀបចំគោលនយោបាយ និងអ្នកអនុវត្ត កំពុងតែស្ថិតក្នុងដំណាក់កាលដំបូងនៃការយល់អំពីទស្សនាទាន និងការអនុវត្តនៃហិរញ្ញប្បទានបៃតងដូច្នេះទាមទារឲ្យមាននូវការក៏សាងសមត្ថភាពក្នុងការរៀបចំតាក់តែងគោលនយោបាយ ទៅលើការប្រមូលទិន្នន័យ ការប៉ានប្រមាណ និងវាយតំលៃគម្រោងជាដើម។

**អនុសាសន៍ទី៦៖** ដើម្បីអភិវឌ្ឍន៍គោលនយោបាយហិរញ្ញប្បទានបៃតង ចាំបាច់ត្រូវមាននិយមន័យច្បាស់លាស់នៃប្រភេទគម្រោងបៃតង និងកំណត់អ្នកពាក់ព័ន្ធសំខាន់ៗ។ ដោយសារការផ្តល់ហិរញ្ញប្បទានបៃតងជាបញ្ហាអន្តរវិស័យ កម្ពុជាគួរតែបង្កើតក្របខ័ណ្ឌទូលំទូលាយមួយសម្រាប់ហិរញ្ញប្បទានបៃតង។ នៅក្នុងផែនការមេហិរញ្ញប្បទានបៃតង ភ្នាក់ងារដឹកនាំ និងភ្នាក់ងារសម្របសម្រួលគួរតែត្រូវបានកំណត់យ៉ាងច្បាស់សម្រាប់ការគ្រប់គ្រង និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព។

## ឯកសារយោង៖


- FFGI Policy Assessment Methodology shttps://fairfinanceguide.org/media/497246/ffg-policy-assessment-methodology-2021.pdf
- ASEAN Taxonomy for Sustainable Finance https://asean.org/wp-content/uploads/2021/11/ASEAN-Taxonomy.pdf
- Taxonomies by Eyes on ESG https://www.eyeonesg.com/tag/taxonomies/
- Green Financing by UNEP https://www.unep.org/regions/asia-and-pacific/regional-initiatives/supporting-resource-efficiency/green-financing
- ASEAN Green Financial Internments Guide https://www.climatebonds.net/files/reports/asean_green_fin_istruments_cbi_012019_0.pdf

- Global Progress Report of the Sustainable Banking Network: Innovation in Policy and Industry Actions in Emerging Markets https://www.ifc.org/wps/wcm/connect/topics_ext_content/ifc_external_corporate_site/sustainability-at-ifc/publications/publications_report_sbnglobalprogress2019

- FFA, Asia’s Dystopian Future?  Why banks need to put sustainable finance clearly in their sights.

- https://asean.org/wp-content/uploads/2021/11/ASEAN-Taxonomy.pdf